# ព្រះរាជក្រម

នស/រកម/០៥១០/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងអំពើភេរវកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម

**មាត្រា ១.—**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម ដែលធ្វើនៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នាថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.—**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣/ល.១០០៥.៤១៤

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៣៧៨ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ខិនកេន

2/24

# អនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងអំពើភេរវកម្ម

បណ្តាប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន (ASEAN) រួមមាន ប្រទេសប្រ៊ុយណេដារ៉ូស្សាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋឥណ្ឌូនេស៊ី សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណៈរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម អំណើះតទៅហៅថា "ភាគី" ។

រំលឹកឡើងវិញនូវធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃច្បាប់អន្តរជាតិដែលពាក់ព័ន្ធ អនុសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធការប្រឆាំងនឹងអំពើភេរវកម្ម និងសេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិស្តីពីបណ្តាវិធានការក្នុងការប្រឆាំងអំពើភេរវកម្មអន្តរជាតិ ព្រមទាំងបញ្ជាក់ឡើងវិញនូវការប្តេជ្ញារបស់យើង ដើម្បីការពារសិទ្ធិមនុស្ស ភាពយុត្តិធម៌ នីតិរដ្ឋ និងដំណើរការតាមនីតិវិធី ក៏ដូចជាគោលការណ៍ដែលបានចែងក្នុងសន្ធិសញ្ញាចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលបានធ្វើនៅកោះបាលី កាលពីថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។

បញ្ជាក់អះអាងឡើងវិញថា អំពើភេរវកម្មមិនអាច ហើយក៏មិនត្រូវបានជាប់ពាក់ព័ន្ធជាមួយនឹងសាសនា សញ្ជាតិ អរិយធម៌ ឬក៏ក្រុមជនជាតិភាគតិចណាមួយឡើយ ។

រំលឹកឡើងវិញផងដែរ នូវសេចក្តីប្រកាសរបស់អាស៊ាន ស្តីពីសកម្មភាពរួមក្នុងការប្រឆាំងអំពើភេរវកម្ម និងសេចក្តីប្រកាសស្តីពីអំពើភេរវកម្មដែលបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ានជាបន្តបន្ទាប់ក្នុងឆ្នាំ ២០០១ និង ២០០២ ។

បញ្ជាក់អះអាងឡើងវិញនូវការប្តេជ្ញារបស់យើងស្របតាមកម្មវិធីសកម្មភាពក្រុងវៀងច័ន្ទ កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ជាពិសេសបង្កើនការជំរុញរបស់ខ្លួនលើការកែសំរួល និងការចែករំលែកនូវបទដ្ឋាន និងសេចក្តីត្រូវការក្នុងចំណោមបញ្ហាផ្សេងៗទៀត ដើម្បីធ្វើការឆ្ពោះទៅរកការសំរេចបង្កើត នៃកិច្ចព្រមព្រៀងលើការជួយផ្នែកច្បាប់ទៅវិញទៅមករបស់អាស៊ាន និងអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ព្រមទាំងធ្វើការបង្កើតឡើងនូវសន្ធិសញ្ញាបត្យាប័នអាស៊ានមួយ ដែលបានគ្រោងទុកតាមរយៈសេចក្តីប្រកាសនៃកិច្ចព្រមព្រៀងអាស៊ាន កាលពីឆ្នាំ ១៩៧៦ ។

មានក្តីបារម្ភយ៉ាងជ្រាលជ្រៅលើគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ដែលបានបង្កដោយអំពើភេរវកម្មដល់អាយុជីវិតជន ស្លូតត្រង់ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន សន្តិភាព និងស្ថេរភាពក្នុងតំបន់ និងអន្តរជាតិក៏ដូចជាការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

យល់ឃើញនូវសារសំខាន់នៃការស្គាល់ច្បាស់ពីអត្តសញ្ញាណ និងការដោះស្រាយប្រកបដោយប្រសិទ្ធិភាពនៃឫសគល់ ដែលបង្កអោយមានអំពើភេរវកម្មក្នុងការរៀបចំយ៉ាងជាក់លាក់នូវបណ្តាវិធានការប្រឆាំងនឹងអំពើភេរវកម្ម ។

បញ្ជាក់ឡើងវិញជាថ្មីម្តងទៀតថា រាល់លក្ខណៈ និងទំរង់គ្រប់ប្រភេទនៃអំពើភេរវកម្មដែលបានកើតឡើង ទោះជានៅកន្លែងណា ពេលណា និងប្រព្រឹត្តដោយអ្នកណាក៏ដោយ គឺជាការគំរាមកំហែងមួយដ៏ខ្លាំងក្លាដល់សន្តិភាព និងសន្តិសុខជាលក្ខណៈអន្តរជាតិ និងគឺជាការប្រឈមដោយផ្ទាល់ចំពោះមុខ ដើម្បីឈានដល់គោលដៅសម្រេចនៃសន្តិភាព វឌ្ឍនភាព និងវិបុលភាពរបស់អាស៊ាន និងការយល់ដឹងអំពីចក្ខុវិស័យអាស៊ានឆ្នាំ ២០២០ ។

បញ្ជាក់អះអាងឡើងវិញពីការប្តេជ្ញាដ៏ខ្លាំងក្លារបស់យើង ដើម្បីបង្កើនទូវកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងនឹងអំពើភេរវកម្មព្រមទាំងធ្វើការទប់ស្កាត់ និងបង្ក្រាបនូវរាល់ទំរង់គ្រប់ប្រភេទនៃសកម្មភាពរបស់ពួកភេរវករ។

បញ្ជាក់ឡើងវិញជាថ្មីម្តងទៀតនូវសេចក្តីត្រូវការដ៏ចាំបាច់ ដើម្បីធ្វើអោយប្រសើរឡើងលើកិច្ចសហប្រតិបត្តិការនៅតាមតំបន់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម និងអនុវត្តនូវបណ្តាវិធានការប្រកបដោយប្រសិទ្ធិភាព តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជ្រាលជ្រៅក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរដែលពាក់ព័ន្ធរបស់អាស៊ានក្នុងការប្រឆាំងទៅនឹងអំពើភេរវកម្ម។

លើកទឹកចិត្តដល់ភាគីទាំងឡាយ ដើម្បីអោយក្លាយជាភាគីក្នុងពេលដ៏ឆាប់ខាងមុខនេះចំពោះអនុសញ្ញា និងពិធីសារអន្តរជាតិ ដែលជាប់ពាក់ព័ន្ធក្នុងការប្រឆាំងទៅនឹងអំពើភេរវកម្ម។

បានព្រមព្រៀងគ្នាដូចខាងក្រោម៖

## មាត្រា ១

### គោលបំណង

អនុសញ្ញានេះផ្តល់នូវគ្រប់ខ័ណ្ឌសំរាប់ធ្វើកិច្ចសហប្រតិបត្តិការនៅតាមតំបន់ ដើម្បីប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងបង្ក្រាបនូវរាល់លក្ខណៈ និងទំរង់គ្រប់ប្រភេទនៃអំពើភេរវកម្ម និងដើម្បីធ្វើកិច្ចសហប្រតិបត្តិការអោយកាន់តែខ្លាំងក្លាឡើងក្នុងចំណោមភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរដែលពាក់ព័ន្ធរបស់ភាគីទាំងឡាយក្នុងការប្រឆាំងនឹងអំពើភេរវកម្ម។

## មាត្រា ២

### សកម្មភាពឧក្រិដ្ឋនៃអំពើភេរវកម្ម

១. ក្នុងគោលបំណងនៃអនុសញ្ញានេះ "បទល្មើស" មានន័យថា បទល្មើសទាំងឡាយណាស្ថិតក្នុងវិសាលភាព និងបានផ្តល់នូវអត្ថន័យដែលបានកំណត់ក្នុងសន្ធិសញ្ញាទាំងឡាយដូចខាងក្រោម៖

ក. អនុសញ្ញា ស្តីពីការបង្ក្រាបលើការចាប់ជំរិតយន្តហោះដោយខុសច្បាប់ ដែលបានចុះហត្ថលេខាកាលថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៧០ នៅឡាហេ្គ។

ខ. អនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល ដែលបានអនុម័តកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧១ នៅម៉ុងត្រេអាល់។

គ. អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះបទល្មើសឧក្រិដ្ឋប្រព្រឹត្តលើបុគ្គល ដែលមានសិទ្ធិការពារជាអន្តរជាតិរួមទាំងភ្នាក់ងារការទូត ដែលបានអនុម័តកាលពី ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៣ នៅទីក្រុងញូវយ៉ក។

ឃ. អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ដែលបានអនុម័តកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ នៅទីក្រុងញូវយ៉ក។

ង. អនុសញ្ញាស្តីពីការការពាររាងកាយពីសាធាតុនុយក្លេអ៊ែរ ដែលបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៧៩ នៅវីអេណា។

ច. ពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពបំពានខុសច្បាប់ នៃអំពើហឹង្សានៅព្រលានអាកាសចរណ៍ស៊ីវិលអន្តរជាតិបន្ថែមទៅលើអនុសញ្ញា ស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងអាកាសចរណ៍ស៊ីវិល បានធ្វើនៅទីក្រុង ម៉ុងត្រេអាល់ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៨៨។

ឆ. អនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងទៅនឹងសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលបានធ្វើនៅទីក្រុងរ៉ូម កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨។

ជ. ពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចិន្ត្រៃយ៍ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្រ បានធ្វើនៅក្នុងទីក្រុងរ៉ូម កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៨៨។

ឈ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់បំផ្ទុះគ្រាប់បែករបស់ពួកភេរវករ ដែលបានអនុម័តកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧ នៅទីក្រុងញូវយ៉ក។

ញ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបលើការផ្តត់ផ្គង់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលបានអនុម័តកាលពីថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៩ នៅទីក្រុងញូវយ៉ក។

ដ. អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបលើសកម្មភាពនៃអំពើភេរវកម្មនុយក្លេអ៊ែរ ដែលបានអនុម័តកាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ នៅទីក្រុងញូវយ៉ក។

ឋ. ការធ្វើវិសោធនកម្ម ចំពោះអនុសញ្ញាស្តីពីការការពាររាង្គកាយពីសារធាតុនុយក្លេអ៊ែរ បានធ្វើនៅវីអេណាកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥។

ឌ. ពិធីសារឆ្នាំ២០០៥ ចំពោះអនុសញ្ញាស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្របានធ្វើនៅទីក្រុងឡុង កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥។

ឍ. ពិធីសារឆ្នាំ ២០០៥ ទៅនឹងពិធីសារស្តីពីការបង្ក្រាបលើសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាព នៃទីតាំងអចិន្ត្រៃយ៍ ដែលស្ថិតនៅតំបន់ខ្ពង់រាបបាតសមុទ្របានធ្វើនៅក្នុងទីក្រុងឡុង កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០០៥។

២. ដំកល់ទុកនូវឯកសាររបស់ខ្លួនស្តីពីការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ភាគីមួយដែលមិនមែនជាភាគីនៃសន្ធិសញ្ញាមួយដែលបានកំណត់ក្នុងកថាខ័ណ្ឌទី១ អាចនឹងប្រកាសថា សន្ធិសញ្ញាមិនត្រូវបានចាត់ទុកថាបានដាក់បញ្ចូលក្នុងកថាខ័ណ្ឌទី១ ចំពោះការអនុវត្តន៍នៃអនុសញ្ញានេះចំពោះភាគីនោះ។ សេចក្តីប្រកាសនេះបានបញ្ឈប់សុពលភាពភ្លាម ខណៈពេលដែលសន្ធិសញ្ញាចូលជាធរមានសំរាប់ភាគីដែលបានធ្វើសេចក្តីប្រកាសខាងលើ ដែលត្រូវជូនដំណឹងដូចបានចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រា២០ នៃការចូលជាធរមាននេះ។

៣. នៅពេលដែលភាគីមួយបញ្ឈប់ជាភាគីមួយចំពោះសន្ធិសញ្ញាមួយដែលបានកំណត់ក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ភាគីនេះអាចធ្វើនូវសេចក្តីប្រកាសមួយផ្តល់សំរាប់មាត្រានេះចំពោះសន្ធិសញ្ញានោះ។

## មាត្រា ៣

## សមភាពអធិបតេយ្យ, បូរណភាពដែនដី និងការមិនជ្រៀតជ្រែក

ភាគីទាំងឡាយត្រូវអនុវត្តន៍នូវកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះ ក្នុងលក្ខណៈមួយស្របទៅតាមគោលការណ៍នៃសមភាពអធិបតេយ្យ និងបូរណភាពដែនដីរបស់ភាគីទាំងឡាយ ហើយនឹងការមិនជ្រៀតជ្រែកនូវរាល់កិច្ចការផ្ទៃក្នុងនៃភាគីទាំងឡាយផ្សេងទៀត។

## មាត្រា ៤

## ការការពារអធិបតេយ្យភាព

នៅក្នុងអនុសញ្ញានេះមិនមានការផ្តល់សិទ្ធិដល់ភាគីណាមួយ ដើម្បីអនុវត្តក្នុងដែនដីនៃភាគីមួយផ្សេងទៀតលើការអនុវត្តនីនូវដែនសមត្ថកិច្ចយុត្តាធិការ ឬក៏បំពេញមុខងារដែលបំរុងទុកយ៉ាងពិសេសចំពោះអាជ្ញាធរ នៃភាគីណាផ្សេងទៀតតាមរយៈច្បាប់ជាតិរបស់ខ្លួន ។

## មាត្រា ៥

## ការមិនអនុវត្តន៍

អនុសញ្ញានេះមិនត្រូវបានយកមកអនុវត្ត នៅពេលណាដែលបទល្មើសបានប្រព្រឹត្តឡើងនៅក្នុងទឹកដីរបស់ភាគីមួយ ជនល្មើសដែលត្រូវបានចោទប្រកាន់ និងជនរងគ្រោះជាពលរដ្ឋនៃភាគីនោះ បទល្មើសដែលបានចោទប្រកាន់ត្រូវបានរកឃើញនៅក្នុងដែនដីនៃភាគីនោះ ហើយភាគីផ្សេងទៀតមិនមានគោលការណ៍ដ៏សំខាន់មួយដែលជាមូលដ្ឋានគ្រឹះ តាមអនុសញ្ញានេះដើម្បីអនុវត្តនូវដែនសមត្ថកិច្ចយុត្តាធិការ ។

## មាត្រា ៦

## វិស័យនានានៃកិច្ចសហប្រតិបត្តិការ

១. វិស័យនានានៃកិច្ចសហប្រតិបត្តិការតាមអនុសញ្ញានេះ រួមមានទាំងបណ្តាវិធានការដ៏សមស្របដោយអនុលោមទៅតាមច្បាប់ជាតិរបស់ភាគីនីមួយៗក្នុងនោះមាន:

ក. ចាត់នូវបណ្តាវិធានការដ៏ចាំបាច់ ដើម្បីទប់ស្កាត់ទៅនឹងការប្រព្រឹត្តនៃសកម្មភាពរបស់ពួកភេរវករ រួមមានទាំងការផ្តល់នូវការក្រើនរំលឹកជាមុនដល់ភាគីផ្សេងៗទៀត តាមរយៈការផ្លាស់ប្តូរពត៌មាន ។

ខ. ទប់ស្កាត់នូវរាល់ជនទាំងឡាយណាដែលផ្តល់ផ្នែកហិរញ្ញវត្ថុ រៀបចំផែនការ ផ្តល់លក្ខណៈងាយស្រួល ឬក៏ប្រព្រឹត្តនូវសកម្មភាពភេរវកម្មពីការប្រើប្រាស់ទឹកដីនីមួយៗរបស់គេក្នុងគោលបំណងប្រឆាំងនឹងភាគីផ្សេងៗទៀត ឬក៏ប្រជាពលរដ្ឋរបស់គេ ។

គ. ទប់ស្កាត់ និងបង្ក្រាបនូវការធ្វើហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម ។

ឃ. ទប់ស្កាត់នូវចលនារបស់ពួកភេរវករ ឬក៏ក្រុមរបស់ពួកភេរវករដោយធ្វើការត្រួតពិនិត្យនៅតាមព្រំដែន និងត្រួតពិនិត្យលើការចេញនូវលិខិតបញ្ជាក់អត្តសញ្ញាណ និងឯកសារធ្វើដំណើរប្រកបដោយប្រសិទ្ធិភាព និងតាមរយៈបណ្តាវិធានការសំរាប់ធ្វើការទប់ស្កាត់ការក្លែងបន្លំលើការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណ និងឯកសារធ្វើដំណើរក្លែងក្លាយ ។

ង. បង្កើនការពង្រឹងសមត្ថភាព រួមមានទាំងការបណ្តុះបណ្តាល ការធ្វើកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស និងប្រារព្ធឡើងនូវកិច្ចប្រជុំនៅតាមតំបន់ ។

ច. ជំរុញអោយមានការយល់ដឹងជាសាធារណៈ និង ការចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រឆាំងនឹងអំពើភេរវកម្មក៏ដូចជាបង្កើននូវកិច្ចពិភាក្សាលើសេចក្តីទុកចិត្តគ្នាទៅវិញទៅមក និងក្នុងផ្នែកលទ្ធិសាសនាព្រមទាំងធ្វើការពិភាក្សាលើផ្នែកអរិយធម៌ជឿនលឿន ។

ឆ. បង្កើនកិច្ចសហប្រតិបត្តិការលើការឆ្លងកាត់ព្រំដែន ។

ជ. បង្កើនការផ្លាស់ប្តូរពត៌មានចារកម្ម និងចែករំលែកពត៌មាន ។

ឈ. បង្កើនកិច្ចសហប្រតិបត្តិការឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យកុំព្យូទ័រ ដែលមានស្រាប់នៅតាមតំបន់ក្រោមវង្វង់សមត្ថកិច្ចរបស់គណៈកម្មាការអាស៊ានដែលពាក់ព័ន្ធ។

ញ. ពង្រឹងនូវសមត្ថភាព និងការរៀបចំទុកជាមុន ដើម្បីដោះស្រាយលើអំពើភេរវកម្មផ្នែកគីមីសាស្ត្រ ជីវសាស្ត្រ វិទ្យុសាស្ត្រ នុយក្លេអ៊ែរ អំពើភេរវកម្មព័ត៌មានវិទ្យា និងរាល់ទំរង់ថ្មីណាមួយនៃអំពើភេរវកម្ម។

ដ. ទទួលខុសត្រូវ ស្រាវជ្រាវរក និងការបង្កើននូវបណ្តាវិធានការ ដើម្បីប្រឆាំងនឹងអំពើភេរវកម្ម។

ឋ. ជំរុញទឹកចិត្តដល់ការប្រើប្រាស់នូវរាល់ឧបករណ៍ សន្និសិទតាមវីដេអូ ឬក៏សន្និសិទតាមទូរទស្សន៍ សំរាប់ចំណាត់ការរបស់តុលាការនៅពេលដែលសមស្រប។

ឌ. ធានាអោយប្រាកដថា ជនណាមួយដែលបានចូលរួមក្នុងការធ្វើហិរញ្ញប្បទាន មានផែនការ ការរៀបចំ ឬក៏ការប្រព្រឹត្តនូវសកម្មភាពភេរវកម្ម ឬក៏ជួយឧបត្ថម្ភដល់សកម្មភាពរបស់ពួកភេរវករត្រូវនាំយកមកកាត់ទោស។

២. អាស្រ័យលើការព្រមព្រៀងគ្នារបស់ភាគីទាំងឡាយដែលពាក់ព័ន្ធភាគីទាំងនោះ ត្រូវធ្វើសហប្រតិបត្តិការ ដើម្បីដោះស្រាយនូវឫសគល់ដែលបង្កអោយមានអំពើភេរវកម្ម និងលក្ខណៈដែលនាំទៅរកការរីករាលដាលនៃអំពើភេរវកម្ម ដើម្បីទប់ស្កាត់លើការប្រព្រឹត្តនូវសកម្មភាពរបស់ពួកភេរវករ និងការកើនឡើងនូវក្រុមតូចៗរបស់ភេរវករ។

## មាត្រា ៧

## ដែនសមត្ថកិច្ចយុត្តាធិការរបស់ភាគី

១. ភាគីមួយត្រូវចាត់នូវបណ្តាវិធានការចាំបាច់សមស្រប ដើម្បីបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ នៅពេលដែល:

ក. បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅក្នុងដែនដីនៃភាគីនោះ ឬក៏

ខ. បទល្មើសត្រូវបានប្រព្រឹត្តឡើងនៅលើនាវាដែលដោតទង់ជាតិនៃភាគីនោះ ឬក៏នៅលើយន្តហោះមួយដែលបានចុះបញ្ជីឈ្មោះតាមច្បាប់នៃភាគីនោះនៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង ឬក៏

គ. បទល្មើស ត្រូវបានប្រព្រឹត្តឡើងដោយពលរដ្ឋម្នាក់នៃភាគីនោះ

២. ភាគីមួយអាចនឹងបង្កើតឡើងផងដែរនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសណាមួយខាងលើ នៅពេលដែល:

ក. បទល្មើសត្រូវបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងពលរដ្ឋម្នាក់នៃភាគីនោះ ឬក៏

ខ. បទល្មើសត្រូវបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងភាគីមួយ ឬក៏សេវាកម្មសាធារណៈរបស់រដ្ឋាភិបាល នៃភាគីនោះ ដែលនៅក្រៅប្រទេស រួមមានទាំងស្ថានទូត ឬក៏ទីបរិវេណកុងស៊ុល ឬក៏ផ្នែកការទូតផ្សេងទៀត របស់ខ្លួន ឬក៏

គ. បទល្មើសត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងមួយដើម្បីបង្ខិតបង្ខំអោយភាគីនោះធ្វើ ឬក៏រារាំងពីការធ្វើសកម្មភាពអ្វីមួយ ឬក៏

ឃ. បទល្មើសត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលម្នាក់ដែលមិនមែនជាពលរដ្ឋនៃប្រទេសណាមួយ ប៉ុន្តែបានស្នាក់នៅជាប្រក្រតីក្នុងដែនដីនៃភាគីនោះ។

៣. ភាគីមួយត្រូវបង្កើតឡើងផងដែរនូវដែនសមត្ថកិច្ចយុត្តាធិការរបស់ខ្លួន អំពីបទល្មើសដែលបានចែងក្នុងមាត្រា២ ក្នុងករណីដែលជនល្មើសត្រូវបានចោទប្រកាន់ មានវត្តមាននៅក្នុងដែនដីរបស់ខ្លួន ហើយភាគីនោះមិនទាន់បានធ្វើបត្យាប័ន ជនល្មើសនោះជូនទៅភាគីទាំងឡាយណា ដែលបានបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការរបស់គេ ដោយអនុលោមទៅតាម កថាខ័ណ្ឌទី ១ ឬ ទី២ នៃមាត្រានេះ។

៤. អនុសញ្ញានេះមិនរាប់បញ្ចូលលើការអនុវត្តន៍នៃដែនសមត្ថកិច្ចយុត្តាធិការព្រហ្មទណ្ឌណាមួយដែលបានបង្កើត ឡើងដោយភាគីមួយដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន។

**មាត្រា ៨**

**ការយកចិត្តទុកដាក់ថែទាំដ៏ត្រឹមត្រូវ**

១. ជនណាដែលត្រូវបានចាប់ឃុំខ្លួន ឬក៏ជាប់ពាក់ព័ន្ធទៅនឹងការចាត់បណ្តាវិធានការ ឬក៏ចំណាត់ការក្តីណា មួយផ្សេងទៀតដែលបានអនុវត្តស្របទៅតាមអនុសញ្ញានេះ ត្រូវបានធានាអោយមានការយកចិត្តទុកដាក់ថែទាំត្រឹមត្រូវរួម មានទាំងការទទួលនូវសិទ្ធិ និងការធានា ដែលអនុលោមទៅតាមច្បាប់ក្នុងដែនដីរបស់ភាគីដែលជននោះមានវត្តមាន និង អនុវត្តនូវរាល់បទបញ្ញត្តិនៃច្បាប់អន្តរជាតិ ដោយរួមមានទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

២. ក្រោយពេលទទួលបានពត៌មានថា មានជនម្នាក់បានប្រព្រឹត្តឬក៏ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តបទល្មើស មួយដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះមានវត្តមានក្នុងទឹកដីរបស់ខ្លួន ភាគីដែលជាប់ពាក់ព័ន្ធ ត្រូវចាត់នូវបណ្តា វិធានការដ៏ចាំបាច់សមស្របតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេតលើហេតុការណ៍ ដែលទាក់ទងទៅនឹងពត៌មាន។

៣. បន្ទាប់ពីបានយល់ព្រមនូវលក្ខណៈនៃការធានាលើជនល្មើស ឬក៏ជនដែលត្រូវបានចោទប្រកាន់មានវត្តមាន ក្នុងដែនដីរបស់ភាគី ភាគីនោះត្រូវចាត់នូវបណ្តាវិធានការដ៏សមស្របទៅតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធានាអោយប្រាកដ ថា វត្តមានរបស់ជននោះក្នុងគោលបំណងធ្វើការកាត់ទោស ឬក៏ធ្វើបត្យាប័ន។

៤. ជនណាដែលជាប់ពាក់ព័ន្ធទៅនឹងការចាត់នូវបណ្តាវិធានការណាមួយ ដែលបានចែងក្នុងកថាខ័ណ្ឌទី៣ នៃមាត្រា នេះត្រូវបានផ្តល់សិទ្ធិ:

ក. ធ្វើការទំនាក់ទំនងដោយមិនបង្អែរបង្អង់យូរជាមួយនឹងតំណាងដ៏សមស្របរបស់ភាគីនៅជិតបំផុត ដែល ជននោះជាពលរដ្ឋ ឬក៏ផ្តល់សិទ្ធិផ្សេងពីនេះ ដើម្បីការពារសិទ្ធិរបស់ជននោះ។

ខ. មកសាកសួរសុខទុក្ខដោយតំណាងណាម្នាក់នៃភាគីនោះ។

គ. ជូនដំណឹងពីសិទ្ធិរបស់ជននោះស្របតាមអនុកថាខ័ណ្ឌ **ក** និង **ខ** កថាខ័ណ្ឌទី៤ នៃមាត្រានេះ។

៥. រាល់សិទ្ធិដែលបានចែងក្នុងកថាខ័ណ្ឌទី៤ នៃមាត្រានេះ ត្រូវបានអនុវត្តន៍ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិរបស់ភាគីដែលជនល្មើស ឬក៏ជនល្មើសដែលត្រូវបានចោទប្រកាន់មានវត្តមានក្នុងដែនដីនោះ អាស្រ័យលើច្បាប់ និងបទបញ្ញត្តិដូចបានចែងខាងលើ ត្រូវមានសុពលភាពពេញលេញផ្តល់អោយក្នុងគោលបំណងសំរាប់សិទ្ធិស្របទៅតាមកថាខ័ណ្ឌ ទី៤ នៃមាត្រានេះ ដែលបានបំរុងទុកមក។

៦. នៅពេលដែលភាគីមួយបានចាប់ឃុំខ្លួនជនណាម្នាក់ ត្រូវជូនដំណឹងជាបន្ទាន់ដោយផ្ទាល់ ឬក៏តាមរយៈអគ្គ លេខាធិការអាស៊ានដោយអនុលោមទៅតាមមាត្រានេះ ភាគីដែលបានបង្កើតឡើងនូវដែនសមត្ថកិច្ចយុត្តាធិការអនុលោម ទៅតាមមាត្រា៧ កថាខ័ណ្ឌទី១ ឬក៏ ទី២ ហើយនឹងប្រសិនបើពិចារណាឃើញថា អាចធ្វើទៅបានភាគីទាំងឡាយណាមួយ ផ្សេងទៀតដែលបានចាប់អារម្មណ៍លើហេតុការណ៍ថា ជននោះស្ថិតក្នុងមន្ទីរឃុំឃាំង និងស្ថិតលើលក្ខណៈដែលធានាការ ការពារដល់ជននោះ។ ភាគីដែលកំពុងស៊ើបអង្កេត យោងទៅតាមកថាខ័ណ្ឌទី២ នៃមាត្រានេះ ត្រូវជូនដំណឹងជាបន្ទាន់

ដល់ភាគីទាំងឡាយ ដែលបានចែងខាងលើ លើការយល់ឃើញរបស់ខ្លួន និងត្រូវបង្ហាញថា ខ្លួនមានបំណងអនុវត្តនូវដែនសមត្ថកិច្ច យុត្តាធិការដែរឬទេ ។

## មាត្រា ៩

## បទបញ្ញត្តិទូទៅ

១. ភាគីទាំងឡាយត្រូវអនុម័តនូវរាល់បណ្តាវិធានការដ៏ចាំបាច់សមស្រប ដោយរួមមានទាំងការបង្កើតច្បាប់ជាតិមានលក្ខណៈសមស្រប ដើម្បីធានាអោយប្រាកដថា រាល់សកម្មភាពឧក្រិដ្ឋត្រូវបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ជាពិសេសនៅពេលដែលវាមានបំណងធ្វើការបំភិតបំភ័យដល់ប្រជាពលរដ្ឋ ឬក៏ដើម្បីបង្ខិតបង្ខំរដ្ឋាភិបាលមួយ ឬក៏អង្គការអន្តរជាតិមួយធ្វើ ឬក៏រារាំងពីការធ្វើសកម្មភាពអ្វីមួយ ដែលស្ថិតក្នុងលក្ខណៈមិនត្រឹមត្រូវ តាមរយៈធ្វើការពិចារណាលើផ្នែកនយោបាយ ទស្សនវិជ្ជា មនោគមវិជ្ជា ជាតិសាសន៍ ជនជាតិភាគតិច សាសនា ឬក៏លក្ខណៈស្រដៀងគ្នាផ្សេងៗទៀត ។

២. អនុលោមទៅតាមមាត្រា៦ នៃអនុសញ្ញានេះ ភាគីទាំងឡាយត្រូវបង្កើតឡើងនូវបណ្តាញទំនាក់ទំនងតាមលទ្ធភាពរវាងបណ្តាភ្នាក់ងារមានសមត្ថកិច្ច ដើម្បីផ្តល់នូវលក្ខណៈងាយស្រួលដល់ការផ្លាស់ប្តូរពត៌មានក្នុងការទប់ស្កាត់ការប្រព្រឹត្តបទល្មើស ដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ។

៣. ជនល្មើសដែលបានចោទប្រកាន់ ដោយភាគីមួយ ត្រូវនាំយកមកកាត់ទោស នៅពេលដែលទទួលបានការស្នើសុំពីភាគីផ្សេងៗទៀត ដែលប្រកាសនូវដែនសមត្ថកិច្ចយុត្តាធិការមានលក្ខណៈដូចគ្នានោះ ធ្វើការទំនាក់ទំនងពីស្ថានភាពនៃករណីបទល្មើសទៅតាមដំណាក់កាលលើចំណាត់ការក្តីណាមួយទៅកាន់ភាគីផ្សេងៗទៀតទាំងនោះ ។

## មាត្រា ១០

## ឋានៈនៃជនភៀសខ្លួន

ភាគីទាំងឡាយត្រូវចាត់នូវរាល់បណ្តាវិធានការដ៏សមស្រប ដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់ជាតិនីមួយៗរបស់ខ្លួន និងដែលជាប់ពាក់ព័ន្ធច្បាប់អន្តរជាតិដែលអាចអនុវត្តបាន រួមមានទាំងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិមុនពេលផ្តល់ជូនពីស្ថានភាពរបស់ជនភៀសខ្លួន ខណៈពេលដែលភាគីទាំងឡាយទទួលស្គាល់ និងផ្តល់ឱ្យពីស្ថានភាពបែបនេះក្នុងគោលបំណងធានាអោយប្រាកដថា អ្នកស្វែងរកសិទ្ធិជ្រកកោនមិនបានមានផែនការផ្តល់លក្ខណៈងាយស្រួល ឬក៏បានចូលរួមក្នុងការប្រព្រឹត្តនូវសកម្មភាពភេរវកម្ម ។

## មាត្រា ១១

## កម្មវិធីស្តារនីតិសម្បទា

ភាគីទាំងឡាយត្រូវខិតខំខ្នះខ្នែង ដើម្បីបង្កើនការចែករំលែកលើការអនុវត្តន៍ប្រកបដោយភាពល្អប្រសើរស្តីពីកម្មវិធីស្តារនីតិសម្បទា រួមមានទាំងការធ្វើសមាហរណកម្មសង្គមឡើងវិញ មានលក្ខណៈសមស្របចំពោះជនទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តនូវបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ជាមួយនឹងទិសដៅលើការទប់ស្កាត់ នូវការប្រព្រឹត្តសកម្មភាពភេរវកម្ម ។

## មាត្រា ១២

## ការជួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្ម

១- ភាគីទាំងឡាយត្រូវចាត់នូវបណ្តាវិធានការដ៏ទូលំទូលាយ ដោយអនុលោមទៅតាមច្បាប់ជាតិនីមួយៗរបស់ខ្លួនលើការជួយដែលជាប់ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ឬក៏នីតិវិធីព្រហ្មទណ្ឌចំពោះបទល្មើសដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ។

២-ភាគីទាំងឡាយត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ដោយអនុលោមទៅតាមសិទ្ធិសញ្ញានោះ នៅពេលដែលភាគីទាំងឡាយនោះជាភាគីចំពោះសិទ្ធិសញ្ញា ស្តីពីការជួយផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្ម បានធ្វើនៅទីក្រុងកូឡាឡាំពួរ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤។

## មាត្រា ១៣

## បត្យាប័ន

១- ជនល្មើសដែលត្រូវបានចោទប្រកាន់មានវត្តមាន នៅក្នុងដែនដីរបស់ភាគីមួយត្រូវគោរពក្នុងករណីអនុវត្តទៅតាមមាត្រា៧ នៃអនុសញ្ញានេះ ប្រសិនបើភាគីនេះមិនបានធ្វើបត្យាប័នចំពោះជននោះ ដើម្បីដាក់ជូននូវករណីបទល្មើសដោយមិនបង្អែបង្អង់យូរទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងធ្វើការកាត់ទោស តាមរយៈចំណាត់ការក្តី ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ភាគីនោះ ទោះបីជាគ្មានការលើកលែង និងថាតើបទល្មើសត្រូវបានប្រព្រឹត្ត ឬក៏មិនបានប្រព្រឹត្តនៅក្នុងដែនដីរបស់ខ្លួន។ អាជ្ញាធរទាំងនោះ ត្រូវធ្វើការសំរេចចិត្តរបស់ខ្លួនស្ថិតក្នុងលក្ខណៈដូចគ្នាទៅតាមករណីនៃបទល្មើសណាមួយផ្សេងទៀត មានលក្ខណៈធ្ងន់ធ្ងរដោយផ្អែកទៅតាមច្បាប់ជាតិរបស់ភាគីនោះ។

២- បទល្មើសដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ត្រូវចាត់ទុកថាបានបញ្ចូលនូវរាល់បទល្មើសទាំងឡាយដែលអាចធ្វើបត្យាប័នបាននៅក្នុងសិទ្ធិសញ្ញាបត្យាប័នណាមួយ ដែលមានស្រាប់រវាងភាគីទាំងឡាយណាមុនពេលអនុសញ្ញានេះចូលជាធរមាន។ ភាគីទាំងឡាយត្រូវអនុវត្ត ដើម្បីបញ្ចូលបទល្មើសខាងលើ ដែលជាបទល្មើសអាចធ្វើបត្យាប័នបាននូវគ្រប់សិទ្ធិសញ្ញាបត្យាប័ន ត្រូវបានបញ្ចប់ជាបន្តបន្ទាប់រវាងភាគីទាំងឡាយនោះ។

៣- នៅពេលដែលភាគីមួយធ្វើល័ក្ខខ័ណ្ឌបត្យាប័ន ដែលមាននៅក្នុងសិទ្ធិសញ្ញាទទួលនូវការស្នើសុំធ្វើបត្យាប័នពីភាគីមួយផ្សេងទៀត ដែលគ្មានសិទ្ធិសញ្ញាបត្យាប័ន ភាគីដែលត្រូវស្នើសុំពិចារណាទៅលើអនុសញ្ញានេះ ដោយផ្អែកលើច្បាប់សំរាប់ធ្វើបត្យាប័នចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន។

## មាត្រា ១៤

## ការលើកលែងបទល្មើសផ្នែកនយោបាយ

មិនមានបទល្មើសទាំងឡាយណា ដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ត្រូវបានចាត់ទុកក្នុងគោលបំណងនៃការធ្វើបត្យាប័ន តាមមាត្រា១៣ នៃអនុសញ្ញានេះ ឬក៏ការជួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមកក្នុងបញ្ហាឧក្រិដ្ឋកម្មតាមមាត្រា១២ នៃអនុសញ្ញានេះ ដូចជាបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជំរុញទឹកចិត្តអោយធ្វើផ្នែកនយោបាយ។ ហេតុដូច្នេះហើយ កាស្នើសុំសំរាប់ការធ្វើបត្យាប័ន ឬក៏ការជួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមក ក្នុងបញ្ហាឧក្រិដ្ឋកម្មផ្អែកលើបទល្មើសខាងលើ មិនត្រូវបានទទួលយកដោយបញ្ជាក់យ៉ាងច្បាស់ថា វាពាក់ព័ន្ធទៅនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសផ្នែកនយោបាយ ឬក៏បទល្មើសដែលជំរុញទឹកចិត្តអោយធ្វើផ្នែកនយោបាយ។

## មាត្រា ១៥

## ការរៀបចំអាជ្ញាធរកណ្តាល ឬរចនាសម្ព័ន្ធសម្របសម្រួល

ភាគីនីមួយៗត្រូវរៀបចំអាជ្ញាធរកណ្តាលមួយមានលក្ខណៈសមស្រប ឬក៏ការសម្របសម្រួលលើរចនាសម្ព័ន្ធដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការតាមអនុសញ្ញានេះ។

## មាត្រា ១៦

## ការអនុវត្តន៍ ការតាមដាន និង ការពិនិត្យឡើងវិញ

គណៈកម្មការតំបន់អាស៊ានដែលពាក់ព័ន្ធបានជាប់ទាក់ទងក្នុងការធ្វើកិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីកាប្រឆាំងនឹងអំពើភេរវកម្ម នឹងទទួលខុសត្រូវលើការត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវការអនុវត្តន៍នៃ អនុសញ្ញានេះ។

## មាត្រា ១៧

### កិច្ចការសម្ងាត់

១- ភាគីនីមួយៗត្រូវរក្សានូវការសម្ងាត់ និងការសម្ងាត់នៃរាល់ឯកសារទាំងឡាយ កំណត់ហេតុ និងព័ត៌មានផ្សេងៗទៀត ដែលទទួលបានមកពីភាគីណាមួយផ្សេងទៀត ក្នុងនោះរួមមានប្រភពធនធាន។

២- ឯកសារ កំណត់ហេតុ ឬក៏ព័ត៌មានផ្សេងៗទៀត ដែលប្រមូលបានជាប់ទាក់ទងទៅនឹងអនុសញ្ញានេះមិនត្រូវបានប្រកាស ឬក៏ចែករំលែកដល់ភាគីណាមួយផ្សេងទៀត រដ្ឋ ឬបុគ្គល លើកលែងតែការព្រមព្រៀងរបស់ភាគីសរសេរជាលាយលក្ខ័អក្សរជាមុនទើបបានផ្តល់ជូននូវឯកសារ កំណត់ហេតុ ឬក៏ព័ត៌មានទាំងនោះ។

## មាត្រា ១៨

### ភាពទំនាក់ទំនងជាមួយនឹងលិខិតតូបករណ៍អន្តរជាតិផ្សេងៗទៀត

អនុសញ្ញានេះនឹងមិនធ្វើអោយប៉ះពាល់ដល់កាតព្វកិច្ចរបស់ភាគីទាំងឡាយ ដែលមានស្រាប់ជាប់ទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្សេងៗទៀត ជាលក្ខណៈអន្តរជាតិ ហើយថែមទាំងមិនរាំងដល់ភាគីទាំងឡាយ នៅពេលដែលភាគីទាំងនោះបានព្រមព្រៀងគ្នា ក្នុងការផ្តល់នូវការជួយឧបត្ថម្ភទៅវិញទៅមកទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្សេងៗទៀត ជាលក្ខណៈអន្តរជាតិ ឬក៏បទបញ្ញត្តិទាំងឡាយនៃច្បាប់ជាតិរបស់ខ្លួន។

## មាត្រា ១៩

### ការដោះស្រាយជម្លោះ

ភាពខុសគ្នា ឬក៏ជម្លោះណាមួយរវាងភាគីទាំងឡាយដែលកើតឡើងពីការបកស្រាយ ឬក៏ការអនុវត្តន៍នូវរាល់បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ត្រូវបានដោះស្រាយដោយសន្តិវិធី តាមរយៈការពិគ្រោះយោបល់ និងការចរចារវាងភាគីទាំងឡាយ តាមរយៈទំនាក់ទំនងការទូត ឬក៏មធ្យោបាយដ៏ស្រុះស្រួលណាមួយផ្សេងទៀត លើការដោះស្រាយនៃជម្លោះដែលបានព្រមព្រៀងគ្នា ខាងលើរវាងភាគីទាំងនោះ។

## មាត្រា ២០

### ការផ្តល់សច្ចាប័ន ការយល់ព្រម និងការដាក់ដំកល់

១. អនុសញ្ញានេះ អាស្រ័យទៅលើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ដោយអនុលោមទៅតាមនីតិវិធីផ្ទៃក្នុងរបស់ភាគីទាំងឡាយ។

២. រាល់ឯកសារច្បាប់ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមរួចហើយនោះ ត្រូវបានដាក់ដំកល់ទុកជូនទៅអគ្គលេខាធិការអាស៊ាន ជាមួយនឹងការជូនដំណឹងជាបន្ទាន់ដល់ភាគីទាំងឡាយផ្សេងៗទៀតលើការដាក់ដំកល់ទុកនេះ។

## មាត្រា ២១

### ការចូលជាធរមាន និងការធ្វើវិសោធនកម្ម

១. អនុសញ្ញានេះនឹងត្រូវចូលជាធរមានរយៈពេល ៣០ថ្ងៃ ស្របទៅតាមការបរិច្ឆេទនៃការដាក់ដំកល់ទុកនូវរាល់ឯកសារចំនួន៦ច្បាប់ ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រម ហើយដាក់ជូនទៅអគ្គលេខាធិការអាស៊ាន

ក្នុងនោះដែរចំពោះតែភាគីទាំងឡាយណាដែលបានដាក់ជូនពិនិត្យនូវរាល់ឯកសារដែលបានធ្វើការផ្តល់សច្ចាប័ន និងការយល់ព្រមហើយនោះ។

២. ចំពោះភាគីណាមួយដែលធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមនូវអនុសញ្ញានេះ បន្ទាប់ពីបានដាក់ដំកល់នូវរាល់ឯកសារចំនួន៦ច្បាប់ លើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមហើយនោះ ប៉ុន្តែឱ្យបានមុនថ្ងៃអនុសញ្ញានេះចូលជាធរមាន។ អនុសញ្ញានេះ ត្រូវជូនដំណឹងផងដែរ ដល់ភាគីនោះ ស្តីពីការបរិច្ឆេទលើការចូលជាធរមាននៃអនុសញ្ញា។

៣. ចំពោះភាគីមួយដែលធ្វើការផ្តល់សច្ចាប័ន និងការយល់ព្រមលើអនុសញ្ញានេះ ក្រោយពីការចូលជាធរមានរបស់ខ្លួន ដោយអនុលោមទៅតាមកថាខ័ណ្ឌទី១ របស់ភាគីនោះ ស្របតាមកាលបរិច្ឆេទនៃការដាក់ដំកល់ទុកនូវឯកសារច្បាប់ដែលបានធ្វើការផ្តល់សច្ចាប័ន ឬក៏ផ្តល់ការយល់ព្រមហើយនោះ។

៤. អនុសញ្ញានេះត្រូវបានកែសម្រួល ឬក៏ធ្វើវិសោធនកម្មនៅពេលណាមួយតាមការយល់ព្រមជាលាយល័ក្ខអក្សរទៅវិញទៅមករបស់ភាគីទាំងឡាយ។ ការកែសម្រួល ឬក៏ការធ្វើវិសោធនកម្មទាំងនោះ ត្រូវចូលជាធរមានតាមកាលបរិច្ឆេទ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមកខាងលើដោយភាគីទាំងឡាយ ព្រមទាំងបង្កើតឡើងជាផ្នែកនៃអនុសញ្ញានេះ។

៥. ការកែសម្រួល ឬក៏ការធ្វើវិសោធនកម្មណាមួយ នឹងមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងឡាយដែលកើតមានឡើង ឬក៏ផ្អែកទៅលើរាល់បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមុនពេលការចូលជាធរមានលើការកែសម្រួល ឬក៏ការធ្វើវិសោធនកម្មខាងលើ។

### មាត្រា ២២

### ការដកខ្លួន

១. ភាគីណាមួយ អាចដកខ្លួនពីអនុសញ្ញានេះ នៅពេលណាមួយបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់ខ្លួន។

២. ការដកខ្លួននឹងត្រូវផ្តល់ដំណឹងតាមរយៈឯកសារច្បាប់មួយពីការដកខ្លួន ដាក់ជូនទៅអគ្គលេខាធិការអាស៊ាន។

៣. ការដកខ្លួននឹងមានសុពលភាពរយៈពេល១៨០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ាន បានទទួលលិខិតតូបករណ៍ ពីការសុំដកខ្លួន។

៤.អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីទាំងឡាយផ្សេងទៀតលើការដកខ្លួនរបស់ភាគីណាមួយ ។

### មាត្រា ២៣

### ការចុះបញ្ជី

អនុសញ្ញានេះត្រូវបានចុះបញ្ជីតាមរយៈអគ្គលេខាធិការអាស៊ាន ជូនទៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ដោយអនុលោមទៅតាមមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

បានធ្វើនៅក្នុងទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ថ្ងៃទី១៣ ខែមករា ឆ្នាំ ២០០៧ ជាភាសាអង់គ្លេស។

បានចុះហត្ថលេខាដោយថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ានទាំង ១០ មានដូចខាងក្រោម:

ព្រះចៅស៊ុលតង់ **HAJI HASSANAL BOLKIAH** នៃប្រទេសប្រ៊ុយណេ ដារ៉ូហ្សាឡឹម

សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

បណ្ឌិត **SUSILO BAMBANG YUDHOYONO** ប្រធានាធិបតី នៃសាធារណៈរដ្ឋឥណ្ឌូនេស៊ី

ឯកឧត្តម **BOUASONE BOUPHAVANH** នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម **DATO'SERI ABDULLAH AHMAD BADAWI** នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី

ឧត្តមសេនីយ៍ **SOE WIN** នាយករដ្ឋមន្ត្រី នៃសហភាពមីយ៉ាន់ម៉ារ

លោកជំទាវ **GLORIA MACAPAGAL-ARROYO** ប្រធានាធិបតី នៃសាធារណៈរដ្ឋហ្វីលីពីន

ឯកឧត្តម **LEE HSIEN LOONG** នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋសិង្ហបុរី

ឧត្តមសេនីយ៍ **SURAYUD CHULANONT** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់

ឯកឧត្តម **NGUYEN TAN DUNG** នាយករដ្ឋមន្ត្រី នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម

# ASEAN CONVENTION ON COUNTER TERRORISM

Member Countries of the Association of Southeast Asian Nations (ASEAN) - Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, hereinafter referred to as "the Parties";

RECALLING the Charter of the United Nations and relevant principles of international law, the relevant international conventions and protocols relating to counter terrorism and relevant resolutions of the United Nations on measures aimed at countering international terrorism, and reaffirming our commitment to protect human rights, fair treatment, the rule of law, and due process as well as the principles enshrined in the Treaty of Amity and Cooperation in Southeast Asia done at Bali on 24 February 1976;

REAFFIRMING that terrorism cannot and should not be associated with any religion, nationality, civilisation or ethnic group;

RECALLING also the ASEAN Declaration on Joint Action to Counter Terrorism and the Declaration on Terrorism adopted at the ASEAN Summits in 2001 and 2002 respectively;

REAFFIRMING our commitment to the Vientiane Action Programme done at Vientiane on 29 November 2004, particularly its thrust on "shaping and sharing of norms" and the need, among others, to work towards the conclusion of an ASEAN Mutual Legal Assistance Agreement, and an ASEAN Convention on Counter Terrorism, and the establishment of an ASEAN Extradition Treaty as envisaged by the 1976 Declaration of ASEAN Concord;

DEEPLY CONCERNED over the grave danger posed by terrorism to innocent lives, infrastructure and the environment, regional and international peace and stability as well as to economic development;

REALISING the importance of identifying and effectively addressing the root causes of terrorism in the formulation of any counter terrorism measures;

REITERATING that terrorism, in all its forms and manifestations, committed wherever, whenever, and by whomsoever, is a profound threat to international peace and security and a direct challenge to the attainment of peace, progress and prosperity for ASEAN and the realisation of ASEAN Vision 2020;

REAFFIRMING our strong commitment to enhance cooperation in countering terrorism which covers the prevention and suppression of all forms of terrorist acts;

REITERATING the need to improve regional cooperation on counter terrorism and undertake effective measures through deepening cooperation among ASEAN law enforcement agencies and relevant authorities in countering terrorism;

ENCOURAGING the Parties to become parties as soon as possible to the relevant international conventions and protocols relating to counter terrorism;

Have agreed as follows:

Article I

Objective

This Convention shall provide for the framework for regional cooperation to counter, prevent and suppress terrorism in all its forms and manifestations and to deepen

cooperation among law enforcement agencies and relevant authorities of the Parties in countering terrorism.

Article II

Criminal Acts of Terrorism

1. For the purposes of this Convention, "offence" means any of the offences within the scope of and as defined in any of the treaties listed as follows:

a. Convention for the Suppression of Unlawful Seizure of Aircraft, signed at The Hague on 16 December 1970;

b. Convention for the Suppression of Unlawful Acts Against the Safety of Civil Aviation, concluded at Montreal on 23 September 1971;

c. Convention on the Prevention and Punishment of Crimes Against Internationally Protected Persons, Including Diplomatic Agents, adopted in New York on 14 December 1973;

d. International Convention Against the Taking of Hostages, adopted in New York on 17 December 1979;

e. Convention on the Physical Protection of Nuclear Material, adopted in Vienna on 26 October 1979;

f. Protocol for the Suppression of Unlawful Acts of Violence at Airports Serving International Civil Aviation, supplementary to the Convention for the Suppression of Unlawful Acts Against the Safety of Civil Aviation, done at Montreal on 24 February 1988;

g. Convention for the Suppression of Unlawful Acts Against the Safety of Maritime Navigation, done at Rome on 10 March 1988;

h. Protocol for the Suppression of Unlawful Acts Against the Safety of Fixed Platforms Located on the Continental Shelf, done at Rome on 10 March 1988;

i. International Convention for the Suppression of Terrorist Bombings, adopted in New York on 15 December 1997;

j. International Convention for the Suppression of the Financing of Terrorism, adopted in New York on 9 December 1999;

k. International Convention for the Suppression of Acts of Nuclear Terrorism, adopted in New York on 13 April 2005;

l. Amendment to the Convention on the Physical Protection of Nuclear Material, done at Vienna on 8 July 2005;

m. Protocol of 2005 to the Convention for the Suppression of Unlawful Acts Against the Safety of Maritime Navigation, done at London on 14 October 2005; and

n. Protocol of 2005 to the Protocol for the Suppression of Unlawful Acts Against the Safety of Fixed Platforms Located on the Continental Shelf, done at London on 14 October 2005.

2. On depositing its instrument of ratification or approval, a Party which is not a Party to a treaty listed in paragraph 1 of this Article may declare that, in the application of this Convention to that Party, that treaty shall be deemed not to be included in paragraph 1 of this Article. This declaration shall cease to have an effect as soon as the treaty enters into force for the Party having made such a declaration, which shall notify the depositary as stated in paragraph 2 of Article XX of this entry into force.

3. When a Party ceases to be a party to a treaty listed in paragraph 1 of this Article, it may make a declaration as provided for in this Article, with respect to that treaty.

Article III

Sovereign Equality, Territorial Integrity and Non-Interference

The Parties shall carry out their obligations under this Convention in a manner consistent with the principles of sovereign equality and territorial integrity of States and that of non-interference in the internal affairs of other Parties.

Article IV

Preservation of Sovereignty

Nothing in this Convention entitles a Party to undertake, in the territory of another Party, the exercise of jurisdiction or performance of functions which are exclusively reserved for the authorities of that other Party by its domestic laws.

Article V

Non-Application

This Convention shall not apply where the offence is committed within a single Party, the alleged offender and the victims are nationals of that Party, the alleged offender is found in the territory of that Party and no other Party has a basis under this Convention to exercise jurisdiction.

Article VI

Areas of Cooperation

1. The areas of cooperation under this Convention may, in conformity with the domestic laws of the respective Parties, include appropriate measures, among others, to:

a. Take the necessary steps to prevent the commission of terrorist acts, including by the provision of early warning to the other Parties through the exchange of information;

b. Prevent those who finance, plan, facilitate, or commit terrorist acts from using their respective territories for those purposes against the other Parties and/or the citizens of the other Parties;

c. Prevent and suppress the financing of terrorist acts;

d. Prevent the movement of terrorists or terrorist groups by effective border control and controls on issuance of identity papers and travel documents, and through measures for preventing counterfeiting, forgery or fraudulent use of identity papers and travel documents;

e. Promote capacity-building including trainings and technical cooperation and the holding of regional meetings;

f. Promote public awareness and participation in efforts to counter terrorism, as well as enhance inter-faith and intra-faith dialogue and dialogue among civilisations;

g. Enhance cross border cooperation

h. Enhance intelligence exchange and sharing of information;

i. Enhance existing cooperation towards developing regional databases under the purview of the relevant ASEAN bodies;

j. Strengthen capability and readiness to deal with chemical, biological, radiological, nuclear (CBRN) terrorism, cyber terrorism and any new forms of terrorism;

k. Undertake research and development on measures to counter terrorism;

l. Encourage the use of video conference or teleconference facilities for court proceedings, where appropriate; and

m. Ensure that any person who participates in the financing, planning, preparation or perpetration of terrorist acts or in supporting terrorist acts is brought to justice.

2. Subject to the consent of the Parties concerned, Parties shall cooperate to address the root causes of terrorism and conditions conducive to the spread of terrorism to prevent the perpetration of terrorist acts and the propagation of terrorist cells.

Article VII

State Jurisdiction

1. A Party shall take such measures as may be necessary to establish its jurisdiction over the offences covered in Article II of this Convention when:

a. The offence is committed in the territory of that Party; or

b. The offence is committed on board a vessel flying the flag of that Party or an aircraft which is registered under the laws of that Party at the time the offence is committed; or

c. The offence is committed by a national of that Party.

2. A Party may also establish its jurisdiction over any such offence when:

a. The offence is committed against a national of that Party; or

b. The offence is committed against a state or government facility of that Party abroad, including its embassy or other diplomatic or consular premises; or

c. The offence is committed in an attempt to compel that Party to do or to abstain from doing any act; or

d. The offence is committed by a stateless person with habitual residence in the territory of that Party.

3. A Party shall likewise establish its jurisdiction over the offences covered in Article II of this Convention in cases where the alleged offender is present in its territory and it does not extradite that person to any of the Parties that have established their jurisdiction in accordance with paragraph 1 or 2 of this Article.

4. This Convention does not exclude the exercise of any criminal jurisdiction established by a Party in accordance with its domestic laws.

Article VIII

Fair Treatment

1. Any person who is taken into custody or regarding whom any other measures are taken or proceedings are carried out pursuant to this Convention shall be guaranteed fair treatment, including enjoyment of all rights and guarantees in conformity with the laws of the Party in the territory of which that person is present and applicable provisions of international law, including international human rights law.

2. Upon receiving information that a person who has committed or who is alleged to have committed an offence covered in Article II of this Convention may be present in its

territory, the Party concerned shall take such measures as may be necessary under its domestic laws to investigate the facts contained in the information.

3. Upon being satisfied that the circumstances so warrant, the Party in whose territory the offender or alleged offender is present shall take the appropriate measures under its domestic laws so as to ensure that person's presence for the purpose of prosecution or extradition.

4. Any person regarding whom measures referred to in paragraph 3 of this Article are being taken shall be entitled:

a. To communicate without delay with the nearest appropriate representative of the State of which that person is a national or which is otherwise entitled to protect that person's rights;

b. To be visited by a representative of that State;

c. To be informed of that person's rights under subparagraphs (a) and (b) of paragraph 4 of this Article.

5. The rights referred to in paragraph 4 of this Article shall be exercised in conformity with the laws and regulations of the Party in the territory of which the offender or alleged offender is present, subject to the provision that the said laws and regulations must enable full effect to be given to the purposes for which the rights accorded under paragraph 4 of this Article are intended.

6. When a Party, pursuant to the present Article, has taken a person into custody, it shall immediately notify, directly or through the Secretary-General of ASEAN, the Parties which have established jurisdiction in accordance with paragraph 1 or 2 of Article VII, and, if it considers it advisable, any other interested Parties, of the fact that such person is in custody and of the circumstances which warrant that person's detention. The Party which is carrying out the investigation referred to in paragraph 2 of this Article shall promptly inform the said Parties of its findings and shall indicate whether it intends to exercise jurisdiction over the said person.

Article IX

General Provisions

1. The Parties shall adopt such measures as may be necessary, including, where appropriate, national legislation, to ensure that offences covered in Article II of this Convention, especially when it is intended to intimidate a population, or to compel a government or an international organisation to do or to abstain from doing any act, are under no circumstances justifiable by considerations of a political, philosophical, ideological, racial, ethnic, religious or other similar nature.

2. Pursuant to Article VI of this Convention, the Parties shall, where possible, establish channels of communication between their competent agencies to facilitate the exchange of information to prevent the commission of offences covered in Article II of this Convention.

3. The Party where the alleged offender is prosecuted shall, upon the request of the other Parties claiming jurisdiction over the same, communicate the status of the case at any stage of the proceedings to those other Parties.

Article X

Status of Refugees

The Parties shall take appropriate measures, in conformity with the relevant provisions of their respective domestic laws and applicable international law, including international standards of human rights, before granting refugee status, where the Parties recognise

and grant such status, for the purpose of ensuring that the asylum seeker has not planned, facilitated or participated in the commission of terrorist acts.

Article XI

Rehabilitative Programmes

The Parties shall endeavour to promote the sharing of best practices on rehabilitative programmes including, where appropriate, social reintegration of persons involved in the commission of any of the offences covered in Article II of this Convention with the objective of preventing the perpetration of terrorist acts.

Article XII

Mutual Legal Assistance in Criminal Matters

1. The Parties shall, in conformity with their respective domestic laws, afford the widest measure of assistance in connection with investigations or criminal proceedings brought in respect of the offences covered in Article II of this Convention.

2. The Parties shall, where they are parties to the Treaty on Mutual Legal Assistance in Criminal Matters done in Kuala Lumpur on 29 November 2004, carry out their obligations under paragraph 1 of this Article in conformity with that Treaty.

Article XIII

Extradition

1. The Party in the territory of which the alleged offender is present shall, in cases to which Article VII of this Convention applies, if it does not extradite that person, be obliged, without exception whatsoever and whether or not the offence was committed in its territory, to submit the case without undue delay to its competent authorities for the purpose of prosecution, through proceedings in accordance with the domestic laws of that Party. Those authorities shall take their decision in the same manner as in the case of any other offence of a grave nature under the domestic laws of that Party.

2. The offences covered in Article II of this Convention shall be deemed to be included as extraditable offences in any extradition treaty existing between any of the Parties before the entry into force of this Convention. The Parties undertake to include such offences as extraditable offences in every extradition treaty to be subsequently concluded between them.

3. When a Party which makes extradition conditional on the existence of a treaty receives a request for extradition from another Party with which it has no extradition treaty, the requested Party may, at its option, and in conformity with its domestic laws, consider this Convention as a legal basis for extradition in respect of the offences covered in Article II of this Convention.

Article XIV

Political Offences Exception

None of the offences covered in Article II of this Convention shall be regarded for the purposes of extradition under Article XIII of this Convention or mutual legal assistance in criminal matters under Article XII of this Convention as a political offence or as an offence connected with a political offence or as an offence inspired by political motives. Accordingly, a request for extradition or for mutual legal assistance in criminal matters based on such an offence may not be refused on the sole ground that it concerns a political offence or an offence connected with a political offence or an offence inspired by political motives.

Article XV

Designation of Central Authorities or Coordinating Structures

Each Party shall designate, as appropriate, a central authority or coordinating structure to enhance cooperation under this Convention.

Article XVI

Implementation, Monitoring and Review

The relevant ASEAN sectoral bodies involved in ASEAN cooperation on countering terrorism shall be responsible for monitoring and reviewing the implementation of this Convention.

Article XVII

Confidentiality

1. Each Party shall preserve the confidentiality and secrecy of documents, records and other information received from any other Party, including the source thereof.

2. No document, record or other information obtained pursuant to this Convention shall be disclosed to or shared with any other Party, State or person except with the prior written consent of the Party which provided such document, record or information.

Article XVIII

Relationship with Other International Instruments

This Convention shall not derogate from obligations subsisting between the Parties pursuant to other international agreements nor, where the Parties agree, shall it prevent the Parties from providing assistance to each other pursuant to other international agreements or the provisions of their respective domestic laws.

Article XIX

Settlement of Disputes

Any difference or dispute between the Parties arising from the interpretation or application of the provisions of this Convention shall be settled amicably through consultation and negotiation between the Parties through diplomatic channels or any other peaceful means for the settlement of disputes as agreed upon between the Parties.

Article XX

Ratification, Approval and Depositary

1. This Convention shall be subject to ratification or approval in accordance with the internal procedures of the Parties.

2. The instruments of ratification or approval shall be deposited with the Secretary-General of ASEAN who shall promptly inform the other Parties of such deposit.

Article XXI

Entry into Force and Amendment

1. This Convention shall enter into force on the 30th (thirtieth) day following the date of the deposit of the 6th (sixth) instrument of ratification or approval with the Secretary-General of ASEAN in respect of those Parties that have submitted their instruments of ratification or approval.

2. For any Party ratifying or approving this Convention after the deposit of the 6th (sixth) instrument of ratification or approval, but before the day the Convention enters into

force, the Convention shall also apply to that Party on the date the Convention enters into force.

3. In respect of a Party ratifying or approving this Convention subsequent to its entry into force pursuant to paragraph 1, it shall enter into force for that Party on the date its instrument of ratification or approval is deposited.

4. This Convention may be modified or amended at any time by mutual written consent of the Parties. Such modification or amendment shall enter into force on such date as shall be mutually agreed upon by Parties and shall form part of this Convention.

5. Any modification or amendment shall not affect the rights and obligations of the Parties arising from or based on the provisions of this Convention before the entry into force of such modification or amendment.

Article XXII

Withdrawal

1. Any Party may withdraw from this Convention at any time after the date of the entry into force of this Convention for that Party.

2. The withdrawal shall be notified by an instrument of withdrawal to the Secretary-General of ASEAN.

3. The withdrawal shall take effect 180 (one hundred and eighty) days after the receipt of the instrument of withdrawal by the Secretary-General of ASEAN.

4. The Secretary-General of ASEAN shall promptly notify all the other Parties of any withdrawal.

Article XXIII

Registration

This Convention shall be registered by the Secretary-General of ASEAN to the United Nations Secretariat pursuant to Article 102 of the Charter of the United Nations.

DONE at Cebu, Philippines, this Thirteenth Day of January in the Year Two Thousand and Seven, in a single original copy in the English language.

For Brunei Darussalam:

HAJI HASSANAL BOLKIAH
Sultan of Brunei Darussalam

For the Kingdom of Cambodia:

SAMDECH HUN SEN
Prime Minister

For the Republic of Indonesia:

DR. SUSILO BAMBANG YUDHOYONO
President

For the Lao People's Democratic Republic:

BOUASONE BOUPHAVANH
Prime Minister

For Malaysia:

DATO' SERI ABDULLAH AHMAD BADAWI
Prime Minister

For the Union of Myanmar:

GENERAL SOE WIN
Prime Minister

For the Republic of the Philippines:

GLORIA MACAPAGAL-ARROYO
President

For the Republic of Singapore:

LEE HSIEN LOONG
Prime Minister

For the Kingdom of Thailand:

GENERAL SURAYUD CHULANONT (RET.)
Prime Minister

For the Socialist Republic of Viet Nam:

NGUYEN TAN DUNG
Prime Minister